ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧*

# សេចក្តីជូនដំណឹងស្តីពីជំនួបពិភាក្សាការងារ រវាងឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយលោកជំទាវ អេឡែន ហ្គោលស្ទីន (Ellen Goldstein) នាយកប្រចាំប្រទេសរបស់ធនាគារពិភពលោក ប្រចាំតំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងកើត និងប៉ាស៊ីហ្វិច

នាព្រឹកថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ **អេឡែន ហ្គោលស្ទីន** (Ellen Goldstein) ដែលត្រូវបានតែងតាំង និងចូលកាន់តំណែងជានាយកប្រចាំប្រទេសរបស់ធនាគារពិភពលោកប្រចាំតំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងកើត និងប៉ាស៊ីហ្វិច ។ គោលបំណងនៃជំនួបពិភាក្សាការងាររបស់លោកជំទាវ **អេឡែន ហ្គោលស្ទីន** គឺការខិតខំពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងកម្ពុជា ជាមួយធនាគារពិភពលោក ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោកជំទាវ **អេឡែន ហ្គោលស្ទីន** ដែលត្រូវបានតែងតាំងចូលបំពេញភារកិច្ចថ្មីនេះ ជាមួយនឹងក្តីរំពឹងយ៉ាងមុតមាំថាវត្តមានរបស់លោកជំទាវ នឹងរួមចំណែកដល់ការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារពិភពលោកឱ្យកាន់តែរឹងមាំថែមទៀត ។ ឯកឧត្តមបណ្ឌិតសភាចារ្យ បានជម្រាបជូនអំពីតម្រូវការអាទិភាពរបស់កម្ពុជា ដែលក្នុងនោះ អាទិភាពសម្រាប់រយៈពេលមធ្យម និងវែងមានដូចជា÷

១) ការអភិវឌ្ឍសមត្ថភាពជំនាញស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ (IDP) សំដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសឧស្សាហកម្មផ្អែកលើពលកម្មជំនាញ,

២) បន្តស្តារ និងកសាងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលគាំទ្រចីរភាពកំណើនសេដ្ឋកិច្ច,

៣) ពង្រឹងវិស័យឌីជីថលឱ្យកាន់តែមានភាពរស់រវើក និងប្រទាក់ក្រឡាក្នុងទូទាំងប្រទេស និង

៤) វិស័យបង្កើនផលិតភាពកសិកម្ម ។

ទន្ទឹមនេះ សម្រាប់រយៈពេលខ្លីចំពោះមុខ រាជរដ្ឋាភិបាល នឹងបន្តផ្តល់អាទិភាពលើវិស័យ÷

១) ការអភិវឌ្ឍជំនាញ ,

២) ការបង្កើនផលិតភាពកសិកម្ម និង

៣) ការលើកកម្ពស់សេវាកម្មវិស័យ ទេសចរណ៍ ។

ជាការឆ្លើយតប លោកជំទាវ **អេឡែន ហ្គោលស្ទីន** បានថ្លែងបញ្ជាក់ឡើងវិញ នូវគោលជំហរច្បាស់លាស់របស់ធនាគារពិភពលោក ក្នុងការបន្តពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងនោះសម្រាប់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២១ ធនាគារពិភពលោកបានវិភាជន៍ថវិកាប្រមាណជាង ៩៤០ លានដុល្លារអាមេរិកបន្ថែមទៀត ។ លោកជំទាវបានសន្យាជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការស្រូបទាញយកថវិកាដែលបានវិភាជន៍ទុកនេះ មកប្រើប្រាស់ឱ្យអស់តាមផែនការ ដែលក្នុងន័យនេះ រាល់ការរៀបចំគម្រោងអនុវត្តជាក់ស្តែង ត្រូវតែស្របតាមតម្រូវការអាទិភាពពិតប្រាកដរបស់រាជរដ្ឋាភិបាលដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កម្ពុជា និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ។ ជាមួយគ្នានេះ លោកជំទាវនឹងខិតខំសម្រួលរាល់នីតិវិធីអនុវត្តគម្រោងឱ្យកាន់តែមានភាពសាមញ្ញ និងងាយអនុវត្តដើម្បីជួយពន្លឿនល្បឿនអនុវត្តគម្រោង ។ ជាថ្មីម្តងទៀត ក្នុងឋានៈជានាយកប្រចាំប្រទេសរបស់ធនាគារពិភពលោក លោកជំទាវបានប្តេជ្ញាចិត្តរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅនៃការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ ។

ចុងបញ្ចប់ ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណចំពោះធនាគារពិភពលោក ដែលមានសុឆន្ទៈខ្ពស់ និងពិតប្រាកដក្នុងការចូលរួមចំណែកដល់កិច្ចអភិវឌ្ឍនៅកម្ពុជា និងបានវាយតម្លៃខ្ពស់ ចំពោះការបង្កើនទំហំហិរញ្ញប្បទានសហប្រតិបត្តិការបន្ថែមទៀតដល់កម្ពុជា ដែលទាំងនេះឆ្លុះបញ្ចាំងអំពីជំនឿជឿជាក់ដ៏មុតមាំរបស់ធនាគារពិភពលោក ចំពោះរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ឯកឧត្តមបណ្ឌិតសភាចារ្យ បានជម្រាបជូនទៀតថា រាជរដ្ឋាភិបាលកម្ពុជាកំពុងមានមហិច្ឆតាថ្មីមួយទៀត គឺការប្រែក្លាយទៅជាប្រទេសអ្នកផ្តល់វិភាគទានដល់សមាគមន៍អភិវឌ្ឍអន្តរជាតិរបស់ធនាគារពិភពលោក (IDA) ដើម្បីចូលរួមចំណែកគាំទ្រកិច្ចអភិវឌ្ឍរបស់បណ្តាប្រទេសក្រីក្រដទៃផ្សេងៗទៀត ដូចដែលកម្ពុជាធ្លាប់បានឆ្លងកាត់ក្នុងរយៈកាលកន្លងមក ។ ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក៏បានជូនពរលោកជំទាវ **អេឡែន ហ្គោលស្ទីន** ឱ្យទទួលបានជោគជ័យ ក្នុងបេសកកម្មថ្មីនេះ ។